# III - ការងារបណ្ដាក្រសួង

## ១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ២០០ ប្រក.សហវ**

**ស្ដីពីការប្រើប្រាស់ជំនួយទ្រទ្រង់ថវិកា និង មូលនិធិបដិភាគ**

**ក្នុងកិច្ចប្រតិបត្តិការពិសេស**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** លេខ ០១ នស ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** លេខ ១០៩៤/៨៣ នស ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពនៃរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើប្រាស់ដោយ ព្រះរាជក្រម នស.រកម ០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រម លេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ គ្រប់គ្រងច្បាប់ ហិរញ្ញវត្ថុ និង ប្រព័ន្ធថវិកា
- បានឃើញព្រះរាជក្រមលេខ ១២៩៥ នស ០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥ ស្ដីពីច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៦

- បានឃើញអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៨២ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីបទបញ្ជាទូទៅលើគណនេយ្យសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ ១ :** កិច្ចប្រតិបត្តិការចំណាយ ក្នុងក្របខ័ណ្ឌថវិការដ្ឋដែលធ្វើហិរញ្ញប្បទានដោយជំនួយបរទេស ឬដោយមូលនិធិបដិភាគក្នុងកិច្ចប្រតិបត្តិការពិសេស ត្រូវអនុវត្តនិងត្រួតពិនិត្យតាមបទបញ្ញត្តិទាំងឡាយនៃ ប្រកាសនេះ ។

**ប្រការ ២ :** សំណើការសន្យាចំណាយទាំងឡាយរបស់ក្រសួងនានាត្រូវផ្ញើផ្ទាល់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ នាយកដ្ឋានគ្រប់គ្រងទុនវិនិយោគស្ថាបនាមូលដ្ឋានជាអ្នកទទួលខុសត្រូវក្នុងការពិនិត្យ និង ធានាអោយមានភាពស្របគ្នានៃគំរោងចំណាយ និងកម្មវិធីប្រើប្រាស់ដែលបានព្រមព្រៀងដោយអ្នកផ្ដល់មូលនិធិ ។

**ប្រការ ៣ :** ការសន្យាចំណាយត្រូវប្រព្រឹត្តឡើងអោយស្របគ្នា តាមនីតិវិធីលទ្ធកម្មទៅតាមទំហំទឹកប្រាក់ដែលបានកំណត់ដោយបទបញ្ជាទាំងឡាយនៃលទ្ធកម្មសាធារណៈ ។

**ប្រការ ៤ :** អាណត្តិបើកប្រាក់ ដែលធ្វើឡើងដោយអាណាប័ក (ក្រសួងបច្ចេកទេស គ្រប់គ្រងគំរោង) ត្រូវផ្ញើជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានហិរញ្ញវត្ថុ ក្រៅប្រទេស) ដើម្បីធ្វើការទូទាត់ ដោយផ្អែកតាមសក្ខីប័ត្រចំណាយនានា ។

**ប្រការ ៥ :** សក្ខីប័ត្រចំណាយទាំងឡាយ ត្រូវបានបង្កើតឡើងតាមលទ្ធកម្មនានា តាមកិច្ចសន្យាប្រគល់សំភារៈ ឬ ការងារតាមវិក្កយប័ត្រ និង តាមឯកសារផ្សេងៗទៀត ជាតឹកតាងនៃគណនេយ្យ ។

**ប្រការ ៦ :** នាយកដ្ឋានគ្រប់គ្រងវិនិយោគស្ថាបនាមូលដ្ឋាន ត្រូវធានានូវភាពត្រឹមត្រូវនៃចំណាយនិងការសន្យា ដែលបានចែងក្នុងប្រការ២ ខាងលើ ។

**ប្រការ ៧ :** ការទូទាត់ចំណាយត្រូវអនុវត្តដោយផ្ទាល់អោយអ្នកផ្គត់ផ្គង់ ឬអោយអ្នកប្រគល់សំភារៈ ឬ ការងារតាមមូលប្បទានប័ត្រ ឬ តាមដីកាបង្វែរដែលរៀបចំឡើងដោយនាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ដើម្បីជូនចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង

ហិរញ្ញវត្ថុ ឬ ដោយអ្នកតំណាងលើគណនីពិសេស ដែលបើកក្នុងនាមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៨ :** នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ត្រូវគ្រប់គ្រងនិងកាន់បញ្ជីគណនេយ្យជំនួយដក់ក្រានូវកិច្ចប្រតិបត្តិការចំណូល និង ចំណាយដែលបានអនុវត្តលើរាល់គណនីពិសេសនៃជំនួយទ្រទ្រង់ថវិកា និង មូលនីធិបដិភាគ ។

**ប្រការ ៩ :** ការត្រួតពិនិត្យពេលក្រោយការអនុវត្តន៍ការងារ ត្រូវធ្វើឡើងដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមក្រសួងបច្ចេកទេសដោយមានការចូលរួមពីតំណាងនាយកដ្ឋានគ្រប់គ្រងវិនិយោគស្ថាបនាមូលដ្ឋានផង ។ របាយការណ៍ទាំងអស់របស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចំលង ជូនទៅអោយនាយកដ្ឋានគ្រប់គ្រងវិនិយោគស្ថាបនាមូលដ្ឋាន ។

**ប្រការ១០:** នាយកដ្ឋានគ្រប់គ្រងវិនិយោគស្ថាបនាមូលដ្ឋាន ត្រូវទទួលបន្ទុករៀបចំរបាយការណ៍ដើម្បីបង្ហាញជូនអ្នកផ្តល់មូលនីធិនៅពេលបញ្ចប់ប្រតិបត្តិការកម្មវិធី ។

**ប្រការ១១:** ការប្រើប្រាស់មូលនីធិបដិភាគដែលបានមកពីជំនួយអន្តរជាតិ ហើយដែលបានផ្ទេរចូលក្រសួងនានា រហូតដល់កាលបរិច្ឆេទនៃការចេញប្រកាសនេះនឹងត្រូវធ្វើការត្រួតពិនិត្យដល់ទីកន្លែង និងផ្អែកលើលិខិតគតិយុត្តនានាដោយក្រុមអធិការកិច្ចហិរញ្ញវត្ថុ។ របាយការណ៍នៃការត្រួតពិនិត្យហិរញ្ញវត្ថុនេះ ត្រូវដាក់ជូនប្រធាននាយកដ្ឋានគ្រប់គ្រងវិនិយោគស្ថាបនាមូលដ្ឋាន ។

**ប្រការ១២:** នាយកខុទ្ទកាល័យ ប្រធានមន្ទីរ និងប្រធាននាយកដ្ឋានពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *